**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី ២៣ ខែ ០៥ ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤១០ អក
ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១
សាលក្រមលេខៈ ៣៨ (ត)
ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣

**គោរពនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣
ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤១០ អក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ៖

ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ២៨ឆ្នាំ ជានីតិជន ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន អាយ.យ្យូ.ភី.អេស ត្រេឌីង ខូ អិល ធីឌី ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] ខេត្តកណ្ដាល ។ (គេចខ្លួន)

ជាប់ចោទពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅក្រុមហ៊ុន អាយ.យ្យូ.ភី.អេស.ត្រេឌីង អាសយដ្ឋាននៅផ្ទះលេខ១ ផ្លូវជាតិលេខ៥ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ដល់ខែកក្កដា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមហ៊ុន អាយ.យ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) តំណាងដោយលោក [redacted] ផេង ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ១ ផ្លូវជាតិលេខ៥ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យក្រុមហ៊ុន អាយ.យ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) តំណាងដោយលោក [redacted] ផេង។

មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

- បានឃើញពាក្យបណ្ដឹង ចុះថ្ងៃទី២៦-០៨-២០២១។
- បានឃើញពាក្យការពារក្តី ចុះថ្ងៃទី០១-០៩-២០២១ របស់មេធាវី [redacted]។
- បានឃើញពាក្យការពារក្តី ចុះថ្ងៃទី២៦-១០-២០២១ របស់មេធាវី [redacted]។



Scanned with CamScanner

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៩៣៤ ដកសស ចុះថ្ងៃទី២១-១២-២០២១។
- បានឃើញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៧៣៣ ដកបចខ ចុះថ្ងៃទី១៤-១១-២០២២។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៤២០ ដក.សព ចុះថ្ងៃទី០២-១២-២០២២។
- បានឃើញដីកាដំណោះស្រាយលេខ ០៦៥ ដក.ដស ចុះថ្ងៃទី១១-០១-២០២៣។
- បានឃើញពាក្យសុំធ្វើជាមេធាវីការពារក្តី ចុះថ្ងៃទី១៩-០១-២០២៣ របស់មេធាវី [redacted]។
- [redacted]ញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៣៦ ដក.ចត ចុះថ្ងៃទី២៤-០១-២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។
- បានឃើញពាក្យសុំធ្វើជាមេធាវីការពារក្តី ចុះថ្ងៃទី២១-០២-២០២៣ របស់មេធាវី[redacted]។

## **នាពេលសវនាការ**

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ផេង នាពេលសវនាការថា៖ ខ្លួនតំណាងឲ្យក្រុមហ៊ុន អាយ.ឃ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD)។ ឈ្មោះ [redacted] ស្រីលីន ចូលធ្វើការនៅក្រុមហ៊ុន អត់ចាំថ្ងៃ ខែ០២ ឆ្នាំ២០២០ មានតួនាទីជាបុគ្គលិកផ្នែកលក់ និងទារប្រាក់ពីផ្សារទំនើប ប្រហែល១៥កន្លែង។ ការប្រមូលប្រាក់តាំងពីគាត់ចូលធ្វើការបានដំណើរធម្មតា រហូតដល់ខែ១១ និងខែ១២ ឆ្នាំ២០២០ ឃើញការប្រមូលប្រាក់មានការរអាក់រអួល ដោយគាត់ប្រាប់មកខាងក្រុមហ៊ុន ថាអតិថិជនមិនទាន់បង់។ បន្ទាប់មកខាងក្រុមហ៊ុនបានឆែកទៅខាងអតិថិជន ឃើញថា ខាងអតិថិជនបានបង់ប្រាក់រួចហើយ តែអត់ឃើញចូលមកខាងគណនេយ្យរបស់ក្រុមហ៊ុនចំនួនទឹកប្រាក់ដែលរកឃើញគឺ ២៩.៧១៦ ដុល្លារអាមេរិក ឃើញក្នុងខែមករា ឆ្នាំ២០២១។ ខាងក្រុមហ៊ុនបានឲ្យឈ្មោះ [redacted] ស្រីលីន មកបំភ្លឺ គាត់ថា គាត់បានយកទៅចាយវាយអស់ហើយ គាត់សន្យាសងមកក្រុមហ៊ុន ១ខែ ចំនួន១០០០ដុល្លារអាមេរិក រួចគាត់បង់បានចំនួន ៣ខែ បានប្រាក់ចំនួន ៣០០០ ដុល្លាអាមេរិក។ ដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ អតិថិជនមួយទៀតផ្សារបាយ័នបានចេញសែកប្រាក់សុទ្ធឲ្យទៅឈ្មោះ [redacted] ស្រីលីន ចំនួន ១០៥៤៩,៨០ ដុល្លារអាមេរិក រួចឈ្មោះ [redacted] ស្រីលីន បានយកបើកប្រាក់ រួចក៏គេចខ្លួន លែងចូលធ្វើការតាំងពីថ្ងៃនោះមក តែក្រុមហ៊ុននៅទាក់ទងគាត់បាន។ រហូតដល់សព្វថ្ងៃទាក់ទងគាត់លែងបាន។ ប្រាក់ដែលឈ្មោះ [redacted] ស្រីលីន យកពីក្រុមហ៊ុនសរុបទាំងអស់ចំនួន ៤០២៦៥,៨០ ដុល្លារអាមេរិក គាត់សងបាន ៣០០០ ដុល្លារអាមេរិក នៅសល់ ៣៧២៦៥,៨០ ដុល្លារអាមេរិក។ បានជាក្រុមហ៊ុនដឹងថាឈ្មោះ [redacted] ស្រីលីន យកប្រាក់របស់ក្រុមហ៊ុនដោយសារអតិថិជនបានជំពាក់លើសថ្ងៃ គឺក្រុមហ៊ុនឲ្យអតិថិជនជំពាក់តែរយៈពេល ៣០ថ្ងៃប៉ុណ្ណោះ។ ចំពោះសែកដែលអតិថិជនចេញឲ្យមកក្រុមហ៊ុនបើអ្នកចេញសែកដាក់ចំឈ្មោះក្រុមហ៊ុន អាយ.ឃ្យូ.ភី.អេស.ត្រេ ឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) ទើបមានតែក្រុមហ៊ុនប៉ុណ្ណោះ មានសិទ្ធិទៅបើកប្រាក់ អ្នកផ្សេងមិនអាចទៅបើកប្រាក់បានទេ។ ប៉ុន្តែចំពោះផ្សារបាយ័នចេញសែកឲ្យទៅឈ្មោះ [redacted] ស្រីលីន គឺបានដាក់ Cash បានន័យថា អ្នកណាក៏បើកបានដែរ។ ចំពោះសែកនេះ ត្រូវបានឈ្មោះ [redacted] ស្រីលីន បើករួចហើយ គឺមានឯកសារធនាគារ។ ចំពោះប្រាក់ ២៩.៧១៦ ដុល្លាអាមេរិក ដែលឈ្មោះ[redacted] ស្រីលីន បានយកគឺជា



Scanned with CamScanner

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

លុយសុទ្ធ។ ក្រុមហ៊ុនទាមទារប្រាក់ពីឈ្មោះ [redacted] ស្រីលីន ចំនួន ៣៧២៦៥,៨០ ដុល្លាអាមេរិក និងទាមទារជំងឺចិត្តចំនួន ២៥០០០ ដុល្លាអាមេរិក។

- តាមចម្លើយរបស់សាក្សីបំភ្លឺឈ្មោះ [redacted] សុជាតា នាពេលសវនាការថា: ខ្លួនអត់ជាប់សាច់ញាតិជាមួយឈ្មោះ [redacted] ស្រីលីន និងអត់ធ្លាប់មានទំនាស់ជាមួយគ្នាទេ។ ពីមុនខ្លួនជាបុគ្គលិកក្រុមហ៊ុន អាយ.យ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) ពីថ្ងៃទី១០.០៣.២០២០ [redacted]១២ ឆ្នាំ២០២១ ខ្លួនជាប្រធានផ្នែកគណនេយ្យ។ នៅក្នុងខែ០១ ឆ្នាំ២០២១ ខ្លួនមើលតាមរបាយការណ៍បង្ហាញពីអតិថិជនជំពាក់ ឃើញមានបាយ័នម៉ាកឃីត និងខេមបូឌាន ស៊ូភើស្ទ័រ មានការបង់យឺតយ៉ាវ ខ្លួនក៏បានសួរទៅឈ្មោះ [redacted] គីមរ៉ុង ដែលគាត់កាន់គណនេយ្យ អតិថិជនជំពាក់ រួចឈ្មោះ [redacted] គីមរ៉ុង ប្រាប់ខ្លួនថាគាត់បានឆែកជាមួយឈ្មោះ ស្រីលីន ហើយ ស្រីលីន ប្រាប់ថា ខាងផ្សារគេអត់ឲ្យគាត់ចេញចូលទេ ដោយសារកូវីដ ពេលនោះខាងក្រុមហ៊ុនផ្អាកផ្តល់ទំនិញឲ្យបាយ័នម៉ាកឃីត រួចទើបខាងផ្សារបាយ័នផ្តល់ដំណឹងមកក្រុមហ៊ុនថាគាត់បានទូទាត់ប្រាក់ឲ្យរួចហើយ និងបានផ្តល់ឯកសារមកក្រុមហ៊ុន។ ចំពោះប្រាក់ដែលឈ្មោះ [redacted] ស្រីលីន ប្រមូលបានពីផ្សារបាយ័ន និងខេមបូឌាន ស៊ូភើស្ទ័រ សរុបចំនួន ២៩៧១៦ ដុល្លាអាមេរិក ហើយឈ្មោះ [redacted] ស្រីលីន សុំបង់ឲ្យក្រុមហ៊ុនវិញ ១ខែ ស្មើ ១០០០ដុល្លារអាមេរិក គាត់បង់បាន ៣ខែ ស្មើ ៣០០០ ដុល្លារអាមេរិក។ ក្រោយពេលដែលឈ្មោះ [redacted] ស្រីលីន យកប្រាក់ក្រុមហ៊ុន ហើយខាងក្រុមហ៊ុនបានស្នើទៅផ្សារបាយ័នចេញជាសែកវិញ។ ថ្ងៃទី១៦.០៧.២០២២ ផ្សារបាយ័ន បានចេញសែកឲ្យឈ្មោះ [redacted] ស្រីលីន ជាសែកCash បានន័យថា អ្នកណាក៏អាចបើកបានចំនួន ១០៥៤៩,៨០ ដុល្លារអាមេរិក។

- តាមចម្លើយរបស់សាក្សីបំភ្លឺឈ្មោះ [redacted] គីមរ៉ុង នាពេលសវនាការថា: ខ្លួនអត់ជាប់សាច់ញាតិជាមួយខាងក្រុមហ៊ុន អាយ.យ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) និងឈ្មោះ [redacted] ស្រីលីន និងអត់ធ្លាប់មានទំនាស់ជាមួយគ្នាទេ។ ខ្លួនចូលធ្វើការនៅក្រុមហ៊ុន អាយ.យ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី នៅឆ្នាំ២០១៦ ដល់សព្វថ្ងៃ។ មានតួនាទីខាងអាក់ខោន (គណនេយ្យករ)។ ពីខែ៥ ទៅខែ១២ ឆ្នាំ២០២០ គឺឈ្មោះ [redacted] ស្រីលីន បានយកប្រាក់ក្រុមហ៊ុនចំនួន ២៩៧១៦ ដុល្លារអាមេរិក បន្ទាប់មកនៅក្នុងខែ៧ ឆ្នាំ២០២១ គាត់បានយកម្តងទៀត ចំនួន ១០៥០០ដុល្លារដោង គាត់បានយកពីផ្សារបាយ័ន ហើយខាងផ្សារបាយ័នចេញជាសែក រួចគាត់បានយកសែកទៅដកពីធនាគារមេយប៊ែង។ ឈ្មោះ [redacted] ស្រីលីន បានសងប្រាក់ទៅក្រុមហ៊ុនវិញចំនួន ៣០០០ ដុល្លារអាមេរិក (សង១ខែ ស្មើ ១០០០ដុល្លារអាមេរិក)។ សព្វថ្ងៃឈ្មោះ [redacted] ស្រីលីន អត់ធ្វើការនៅក្រុមហ៊ុន អាយ.យ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) ទៀតទេ ដោយសារក្រុមហ៊ុនបញ្ឈប់។

- មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានការពារថា: ផ្អែកតាមអង្គហេតុភស្តុតាង និងអង្គច្បាប់ខាងលើ ខ្លួនសូមធ្វើការសន្និដ្ឋាន: តាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថាជាអំពើការរំលោភលើទំនុកចិត្ត លុះត្រាតែបំពេញលក្ខខណ្ឌដូចជា៖ ១.គែ



Scanned with CamScanner

បំបាត់មូលនិធិតម្លៃ ឬទ្រព្យសម្បត្តិ ២.នាំឲ្យខូចប្រយោជន៍អ្នកដទៃ និង ៣.ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឲ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រម ដោយមានភារកិច្ចប្រគល់សងវិញបង្ហាញ ឬយកមូលនិធិតម្លៃ ឬទ្រព្យសម្បត្តិនោះទៅធ្វើការប្រើប្រាស់ជាកំណត់។ តាមរយៈអង្គហេតុ និងភស្តុតាងខាងលើបង្ហាញថា ក្រុមហ៊ុនបានតែងតាំងឲ្យឈ្មោះ [redacted] ស្រីលីន ធ្វើជាអ្នកប្រមូលប្រាក់ថ្លៃទូទាត់ផលិតផលពីអតិថិជន ហើយមានភារកិច្ចត្រូវប្រគល់ប្រាក់នោះមកឲ្យក្រុមហ៊ុនជាកំណត់ ប៉ុន្តែនៅពេលឈ្មោះ [redacted] ស្រីលីន ទទួលបានប្រាក់ទូទាត់ពីអតិថិជនហើយ ឈ្មោះ [redacted] ស្រីលីន មិនបានយកមកប្រគល់ឲ្យក្រុមហ៊ុនទេ បែរព្យាយាមបង្កើតអង្គហេតុកុហកដើម្បីគៃបំបាត់យកប្រាក់ ដែលជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះទៅធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួនឯង ហើយដោយសារតែហេតុនេះបានធ្វើឲ្យក្រុមហ៊ុនខូចខាតទ្រព្យសម្បត្តិ ព្រមទាំងកេរ្តិ៍ឈ្មោះជាមួយអតិថិជនទៀតផង។ សរុបសេចក្តីមក ឈ្មោះ [redacted] ស្រីលីន ពិតជាបានប្រព្រឹត្តអំពើដែលមានចែងច្បាស់ តាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា និងដោយមានចេតនាទុច្ចរិតដូច្នេះមានជាតុផ្សំបទល្មើសគ្រប់គ្រាន់ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៩២ និងមាត្រា ៣៩៦ នៃក្រមព្រហ្មទណ្ឌ។ សូមសំណូមពរដូចខាងក្រោម៖

១.ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ស្រីលីន ភេទស្រី ឆ្នាំកំណើត១៩៩៣ ជនជាតិខ្មែរ កាន់លិខិតឆ្លងដែនលេខ N០១១៨២២៥៥៤ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ៨២ ភូមិទួលងោក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល។

២.ផ្តន្ទាទោសឈ្មោះ [redacted] ស្រីលីន ភេទស្រី ពីបទៈ រំលោភលើទំនុកចិត្ត ឲ្យបានធ្ងន់ធ្ងរបំផុត។

៣.បង្គាប់ឲ្យឈ្មោះ [redacted] ស្រីលីន សងប្រាក់ចំនួន USD ៣៧,២៦៥.៨០ (សាមសិបប្រាំពីរពាន់ពីរយហុកសិបប្រាំដុល្លារអាមេរិក និងប៉ែតសិបសេន) មកឲ្យក្រុមហ៊ុនវិញ។

៤.បង្គាប់ឲ្យឈ្មោះ [redacted] ស្រីលីន សងសំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសោហ៊ុយថ្លៃសេវាកម្មផ្លូវច្បាប់ និងមេធាវីគិតជាទឹកប្រាក់សរុបចំនួន $២៥,០០០ (ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) មកឲ្យក្រុមហ៊ុន។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន គាត់ពុំនអវត្តមាននៅនីតិវិធីរបស់តុលាការនៅដំណាក់កាលអយ្យការ ក៏ដូចជាចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរក៏បានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនផងដែរ។ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបក្លី គឺមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ពីបទ រំលោភលើទំនុកចិត្ត តំណាងអយ្យ[redacted]ការចោទប្រកាន់លើឈ្មោះ [redacted] ស្រីលីន ពីបទរំលោភលើទំនុកចិត្ត ដដែល និងស្នើសុំផ្តន្ទាទោសតាមច្បាប់។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថាៈ ចំពោះការលើកឡើងពីសែកមិនមានភស្តុតាង បញ្ជាក់ថា ការបើកសែកនេះ គឺត្រូវបានធ្វើឡើងដោយឈ្មោះ [redacted] ស្រីលីន ទេ សូម



Scanned with CamScanner

បដិសេធចោល។ កិច្ចព្រមព្រៀងទូទាត់បំណុល ចុះថ្ងៃទី២១.០១.២០២១ មិនបញ្ជាក់ពីការកិបកេងប្រាក់ពីក្រុមហ៊ុនទេ តែបានបញ្ជាក់ថា ឈ្មោះ [redacted] ស្រីលីន ពិតជាបានជំពាក់ប្រាក់ក្រុមហ៊ុនពិតប្រាកដមែន ដូច្នេះ ក្នុងកិច្ចព្រមព្រៀងនេះ គ្មានសញ្ញាណនៃអំពើល្មើសដែលអាចចោទនៅក្នុងបទព្រហ្មទណ្ឌ ពីបទរំលោភលើទំនុកចិត្ត។ សំណូមពរបង្វែរបទចោទនេះទៅជារឿងក្តីរដ្ឋប្បវេណីវិញ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ក្រឡាបញ្ជី

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីបំភ្លឺ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាងនានា

[redacted] ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សីបំភ្លឺមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងពាក្យបណ្តឹង ចុះថ្ងៃទី២៦-០៨-២០២១ របស់ក្រុមហ៊ុន អាយ.ឃ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) តំណាងដោយលោក [redacted] ផង ព្រមទាំងលិខិតគតិយុត្តនានា ដែលអាចបញ្ជាក់បានថា: ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ជាអតីតបុគ្គលិកនៅក្រុមហ៊ុន អាយ.ឃ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) មានតួនាទីជាបុគ្គលិកផ្នែកលក់ និងទារប្រាក់ពីផ្សារទំនើបប្រហែល ១៥ កន្លែង បានធ្វើសកម្មភាពយកប្រាក់របស់ក្រុមហ៊ុនដែលប្រមូលបានពីផ្សារទំនើប ចំនួន ២ លើក។ ដោយលើកទី១ នៅចន្លោះខែឧសភា ឆ្នាំ២០២០ រហូតដល់ខែធ្នូ ឆ្នាំ២០២០ ឈ្មោះ [redacted] ស្រីលីន បានយកប្រាក់ក្រុមហ៊ុនដែលប្រមូលបានពីផ្សារទំនើបចំនួន USD ២៩,៧១៦ (ម្ភៃប្រាំបួនពាន់ប្រាំពីររយដប់ប្រាំមួយដុល្លារអាមេរិក)។ ក្រោយពីក្រុមហ៊ុនបានដឹងអំពីរឿងនេះ ខាងក្រុមហ៊ុនក៏បានផ្តល់ឱកាសឱ្យឈ្មោះ [redacted] ស្រីលីន កែខ្លួន ហើយឈ្មោះ [redacted] ស្រីលីន ក៏បានសងប្រាក់មកឱ្យខាងក្រុមហ៊ុនវិញបានតែចំនួន USD ៣០០០ (បីពាន់ដុល្លារអាមេរិក) តែប៉ុណ្ណោះ។ លើកទី២ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] ស្រីលីន បានបន្តលួចយកប្រាក់របស់ក្រុមហ៊ុនម្តងទៀត ដែលជាប្រាក់ប្រមូលបានពីផ្សារទំនើបបាយ័ន ដោយពេលនោះផ្សារបាយ័នបានទូទាត់ប្រាក់តាមមូលប្បទានប័ត្ររបស់ធនាគារ May Bank លេខ ៩៥១៧៥៦ ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០២១ មានទឹកប្រាក់ចំនួន USD ១០,៥៤៩.៨០ (ដប់ពាន់ប្រាំរយសែសិបប្រាំបួនដុល្លារអាមេរិក និងប៉ែតសិបសេន) រួចក៏បានរត់គេចខ្លួនបាត់តែម្តង សរុបទាំងអស់ឈ្មោះ [redacted] ស្រីលីន បានយកប្រាក់របស់ក្រុមហ៊ុនចំនួន USD ៣៧,២៦៥.៨០ (សាមសិបប្រាំពីរពាន់ពីររយហុកសិបប្រាំដុល្លារអាមេ



Scanned with CamScanner

រិក និងប៉ែតសិបសេន) ឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ជាបទល្មើសរំលោភលើទំនុកចិត្ត ប្រាកដមែន។

២-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន គឺជាអំពើដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។

៣-ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ជានីតិជន មានស្មារតីយល់ដឹងនិងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសព្រហ្មទណ្ឌ ដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។

៤-ពុំមានភស្តុតាងជាឯកសារ ឬសេចក្តីបញ្ជាក់ណាមួយពីសាក្សីជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលបានបង្ហាញថាជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ជាជនកើតវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការយល់ដឹងខុសត្រូវរបស់ខ្លួន ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដូចមានបញ្ញត្តិក្នុងមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌនោះទេ។

៥-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ២៨ឆ្នាំ ពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅក្រុមហ៊ុន អាយ.ឃ្យូ.ភី.អេស.ត្រេឌីង អាសយដ្ឋាននៅផ្ទះលេខ៦១ ផ្លូវជាតិលេខ៥ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ដល់ខែកក្កដា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៦-តាមការប្តឹងសុំរបស់តំណាងអយ្យការមកតុលាការឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ពីបទៈ រំលោភលើទំនុកចិត្ត តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។ តុលាការយល់ឃើញថាៈ ការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ គប្បីតុលាការសម្រេចតាមការប្តឹងសុំ។

៧-ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន គេចខ្លួន គឺជាចេតនាគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ ដូច្នេះ ដើម្បីធានាដល់ការអនុវត្តទោស ក៏ដូចជារក្សាសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម គប្បីតុលាការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ២៨ឆ្នាំ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៨-ដើមបណ្តឹងរដ្ឋប្បវេណីក្រុមហ៊ុន អាយ.ឃ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) តំណាងដោយលោក [redacted] ផេង ប្តឹងទាមទារៈ

- ប្រាក់ដែលបាត់បង់ចំនួន USD ៣៧,២៦៥.៨០ (សាមសិបប្រាំពីរពាន់ពីររយហុកសិបប្រាំដុល្លារអាមេរិក និងប៉ែតសិបសេន) ។

- សំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសោហ៊ុយថ្លៃសេវាកម្មផ្លូវច្បាប់ ជាប្រាក់សរុបចំនួន ២៥,០០០$ (ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក)។ គប្បីតុលាការពិចារណាតាមទំហំព្យសនកម្មដែលបានកើតឡើងជាក់ស្តែង ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

[redacted]



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

**១**-ផ្តន្ទាទោស: ជនជាប់ចោទឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ១៨ (ដប់ប្រាំបី) ខែ និងពិន័យជាប្រាក់ចំនួន ៣.០០០.០០០៛ (បីលាន) រៀល ។

ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅក្រុមហ៊ុន អាយ.ឃ្យូ.ភី.អេស.ត្រេឌីង អាសយដ្ឋាននៅផ្ទះលេខ១ ផ្លូវជាតិលេខ៥ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ដល់ខែកក្កដា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

**២**-ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ២៨ឆ្នាំ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៣**-បង្គាប់ឲ្យឈ្មោះ [redacted] ស្រីលីន សងប្រាក់ដែលបាត់បង់ចំនួន USD ៣៧.២៦៥,៨០ (សាមសិបប្រាំពីរពាន់ពីររយហុកសិបប្រាំដុល្លារអាមេរិក និងប៉ែតសិបសេន) និងសងសំណងជំងឺចិត្តជាប្រាក់ចំនួន ៨.០០០.០០០៛ (ប្រាំបីលាន) រៀល ទៅក្រុមហ៊ុន អាយ.ឃ្យូ.ភី.អេស.ត្រេឌីង ខូ អិលធីឌី (I.Q.P.S TRADING CO.,LTD) ដែលតំណាងដោយលោក [redacted] ផេង ជាដើមបណ្តឹងរដ្ឋប្បវេណី។ ការទាមទារលើសពីនេះត្រូវច្រានចោល។

**៤**-សាលក្រមនេះជំនុំជម្រះជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ។

" ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ "

| **ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា៖ [redacted] | ហត្ថលេខា និងត្រា៖ [redacted] |

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃព្រហស្បតិ៍ ១កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦
កណ្តាល, ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ខេត្តកណ្តាល ថ្ងៃទី២៣ ខែ ០៥ ឆ្នាំ២០២៣ [redacted]
ក្រឡាបញ្ជី
[redacted]